កាមរាគា

១. ឱកាមរាគា កិលេសតណ្ហា
មាត្រាទាំងឡាយ វាតែងធ្វើទុក្ខ
ធ្វើទោសអន្តរាយ ឱ្យសត្វសម្លាយ
ភ្លេចទាំងក្តីគាប់។

២. មួយភ្លេចសីលទាន ភ្លេចធម៌ដំបូន្មាន
ភ្លេចសត្រាច្បាប់ ភ្លេចទាំងស្មារតី
ប្រយោជន៍ក្តីគាប់ ភ្លេចទាំងខ្លួនស្លាប់
ពុំដឹងឡើយណា។

៣. រីឯកិលេស បើអ្នកណាធ្វេស
បណ្តោយចិត្តវា អ្នកនោះនៅលុះ
សោយទុក្ខវេទនា ឯក្អែកនោះគួរ
គិតអនិច្ចា។

៤. ហែសប្បុរសជង ចូលស្តាប់ត្រាប់ត្រង់
យកទុកគ្រប់គ្នា ក្រែងទៅឯមុខ
កើតទុក្ខវេទនា គួរតែអនិច្ចា
រូបមនុស្សសព្វថ្ងៃ។

៥. អស់ទាំងសម្បត្តិ វានឹងខ្វាយខ្វាត់
ព្រាត់ទៅទីទៃ ប្រពន្ធកូនចៅ
ញាតិដៅជង់ក្តី ទាំងខ្ញុំប្រុសស្រី
សឹងទុកនៅអាយ។

៦. វិញ្ញាណអាត្មា ម្នាក់ឯងកំព្រា
យមភូបាលចងវ៉ាយ បណ្តើរនាំទៅ
ដល់នរកទាយ យមភូបាលចងវ៉ាយ

មួយរយដងមួយថ្ងៃ។

៧. គួរតែធ្វើបុណ្យ ចែកចាយទ្រព្យធន
កុំទុកសំចៃ ទាន់ខ្លួនរស់នៅ
ប្រសើរជាក្រៃ បើទុកសំចៃ
ស្មើស្អប់ខ្លួនទេ។

៨. កាលរស់នៅឡើយ ត្រង់ណាហៅស្បើយ
ទុក្ខឥតមានល្ហែ ពីក្មេងដល់ចាស់
គួរគិតឱ្យថេរ វាឥតមានល្ហែ
ត្រង់កម្មវិបាក។

៩. ហុកសិបឆ្នាំហោង កើតឯឈឺខ្នង
ធ្មេញបាក់ស្រយ៉ាក នេត្រាងងឹត
ហេតុកម្មវិបាក មាត់ខុបស្រយ៉ាក
ត្រចៀកថ្លង់ផង។

១០. ថយទាំងកម្លាំង ខ្លួនប្រាណស្គមស្គាំង
សក់ស្កូវសោតហោង នេះឯងរាជទូត
មកតឿនមនុស្សផង មួយថ្ងៃពាដង
គួរតែអនិច្ចា។

១១. កាលណាបើយប់ គន់ឱ្យសព្វគ្រប់
ប្រះខ្លួនដេកផ្ងារ យកដៃគងថ្ងាស់
រំពឹងគិតថា កាលនឹងមរណា
បានអ្វីទៅផង។

១២. កុំថាទ្រព្យជា ទោះតែអាត្មា
មិនអស់ទៅផង ក្អែកត្មាតចឹកជី
ឆ្អឹងសរគីង ប្រាក់មួយស្លឹងហោង
ដែលគេបង់មាត់។

១៣.　សឹងចោលខាននៅ　ប្រពន្ធកូនចៅ
ទាំងទ្រព្យសម្បត្តិ　ទាសីទាសា
មានទាខ្វាយខ្វាត់　គ្នាគ្មីព្រោយព្រាត់
បង់ទាំងគ្រឹះស្ថាន។

១៤.　បើអ្នកឯណា　មានញាតិកា
បងប្អូនព្រៀងលាន　កូនចៅឯក្រោយ
កម្រនឹងមាន　ធ្វើបុណ្យឱ្យទាន
ខ្លាចអស់ទ្រព្យនោះ។

១៥.　យកតែខ្ចីខ្ចារ　បានផ្ទាំងបាយស្រា
ធ្វើបុណ្យចំពោះ　កន្ទេលដាច់ដាយ
កាំបិតបន្ទោះ　ទ្រព្យល្អពីនោះ
ទុកចេញចែកគ្នា។

១៦.　ខ្លះចិត្តអប្បល័ក្ខណ៍　យកគ្រឿងមាសប្រាក់
លួចលាក់ម្នីម្នា　បណ្ដោះដៃចេញ
ពីគ្រឹហាណា　ហើយពើធ្វើជា
មារយាទរិះរក។

១៧.　ត្បិតតែគ្រឿងមាស　កាត់គ្នាជារាស
ជាក្ដីអំពល់　បំបែករកច្បាប់
ដោយខ្លួនរចល់　នាំគ្នាទៅដល់
ចៅក្រមក្នាក់ងារ។

១៨.　រីឯគ្រឿងមាស　មានកាលវាប្រាស
អន្តរធានអស់　ចូលជាកំណាស់
សូន្យសោះឥតការ　បានទៅក្នាក់ងារ
មុខមន្ត្រីផង។

១៩.　ធ្វើបុណ្យនឹងរីង　ក្រញើកក្រញីង

ប្រឈ្លោះគ្នាកង ដដែកចង់បាន
មាសប្រាក់កែវកង មិនបានដូចប៉ង
ធ្វើទាំងខ្ជីខ្ជា។

២០. បើធ្វើបុណ្យស្រេច បានទ្រព្យរំពេច
រួសរាន់ម្នីម្នា ចែកចាយកូនចៅ
ផៅញាតិកា រួចហើយទើបលា
ទៅស្ថានទីទៃ។

២១. បើព្រៀងមកសួរ ធ្វើឯងខ្សឹកខ្សួល
ធ្វើយំអាល័យ គក់ទ្រូងគក់ស្មា
ហាក់ថាសង្ស័យ ធ្វើពើនោះនៃ
និយាយកាច់ក។

២២. ធ្វើជាកាន់ទុក្ខ ស្លៀកសដូចកុក
សប្បាយត្រេកអរ នឹងសាច់សន្តាន
ព្រៀងលានកុះករ ផ្លាស់សំពត់ស
ស្លៀកខ្មៅស្រងាត់។

២៣. បើកាលឯណា កើតកម្មជរា
ជម្ងឺឈឺថ្កាត់ ទោះរកហោរា
ឯណាចាប់ចុត បញ្ជាន់មេមត់
ទាំងយប់ទាំងថ្ងៃ។

២៤. ហោរមើលហើយថា សព្វប្ញក្សចត្វា
បូកហាសេសសៃ ត្រូវខ្មោចអាពុក
និងម្តាយខឹងក្រៃ ទាំងអារក្សព្រៃ
របក្សាជង។

២៥. ហោរបង្គាប់ថា ឲ្យសែនមេបា
ចាស់ទុំបានម្តង ស៊ុតមាន់ស៊ុតទា

ញាំភ្លាបង្កង ត្រីសាច់ស្រាផង

បង់បាយបីថ្ងៃ។

២៦. រីឯអារក្ស ជាន់មកងងាក់

យកទៀនច្ចុះដៃ ថាដូនកុំគិត

ប្រចិត្តឡើយនៃ លៀងពីរបីថ្ងៃ

សែនដូនពែផង។

២៧. ជម្ងឺដូននោះ យើងយល់ចំពោះ

................ ត្រូវខ្មោចអារក្ស

ក្នុងផ្ទះឯងហោង បានជាថ្កាំថ្កុង

ខុសត្បិតកោរក្បាល។

២៨. ជាន់រូបរំពេច រួសរាន់ស្រាប់ស្រេច

រករៀបអាហារ នឹងសែនចាស់ទុំ

ដោយគ្រោះហោរថា អស់បណ្ដាការ

លើកចោលទៅហោង។

២៩. ទើបហៅអស់ញាតិ ស្លៀកពាក់ស្អាងស្អាត

បង់បោយញ៉ែងញ៉ង ឡើងទៅលើផ្ទះ

សំពះអង្វរ អង្វរខ្មោចផង

ទ្រហឹងគ្រប់គ្នា។

៣០. ទើបរកចាស់ទុំ ឯណាសក្តិសម

ជាអ្នកផ្គង់ស្រា លើកដៃទៅលើ

ស្រេចហើយទើបថា អស់លោកមេបា

ជីដូនជីតា។

៣១. ត្បិតលោកស្លាប់ទៅ ឲ្យអស់កូនចៅ

ពុំសូវសាន្តសុខ ដឹងតែឈឺថ្កាត់

មិនស្បើយត្រង់ទុក្ខ ពុំដែលមានសុខ

ក្នុងអង្គអាត្មា។

៣២. អញ្ជើញលោកមក បាយទឹកពេញស្លក
ត្រីសាច់ញាំភ្លា នាមហៅតែសែន
មិនស្រេកទាំងស្រា ខ្លាចខាតផងវា

នឹងផឹកមិនគ្រាន់។

៣៣. ស្រេចទើបលើកស្លក ជញ្ជូនចេញមក
ហៅគ្នាផឹកស៊ី វីវក៉ុះករ
ក៏តាន់តាប់ម្នី- ម្នារួសរាន់ទៅ

ផ្ទះដោយទីទៃ។

៣៤. គួរគិតអនិច្ចា កាលរស់នៅជា
មនុស្សសព្វថ្ងៃ បរិភោគអាហារ
ឥតឯសង្ស័យ អស់ទាំងចំណី

ឥតឯមានខ្វះ។

៣៥. ស្លាប់ទៅជាខ្មោច ម្នាក់ឯងត្រមោច
កំព្រាសូន្យសោះ បើគេនឹងសែន
គេនឹកតែឈ្មោះ ចំណីទាំងនោះ

ពេញនៅដដែល។

៣៦. មើលឯសំណែន រៀបមកនឹងសែន
ទាំងភក់ទាំងក្អែល អាហារចំណី
ដាក់លើកន្ទេល ដោយដីដដែល

នោះថាស្មោះក្រៃ។

៣៧. បើដូច្នេះណា គួរនឹកអនិច្ចា
សង្វេគសព្វថ្ងៃ កុំអាងមានទ្រព្យ
សម្បត្តិនោះនៃ ខ្លួនឯងក្សិណក្ស័យ

ពុំដឹងឡើយណា។

៣៨. មិនមានកំណត់ ព្រះកាលលោកកត់
ដាក់ដៃគ្រប់គ្នា នឹងងាយរៀបស្បៀង
ប្រដាប់អាត្មា យកទៅភោក្តា
នាកាលនោះហោង។

៣៩. ព្រះបន្ទូលថា កើតក្នុងអវិជ្ជា
ងងឹតកន្លង ស្តែងស្តេចទេសនា
ទុកឲ្យសត្វផង គួរតែត្រាប់ត្រង
កុំភ្លេចឡើយណា។

៤០. រំពូកអាត្មា ក្រែងធ្វើចាឈា
ជាអចិន្ត្រៃ កាមេសុរា
មុសាដោយនៃ អធិដ្ឋាក្រក្រៃ
ហៅបញ្ចុរវេរា។

៤១. រីសីលទាំងប្រាំ ព្រះបន្ទូលផ្តាំ
សព្វសត្វនានា កាន់យកឲ្យខ្ជាប់
សម្រាប់អាត្មា បើឃ្លាតហើយណា
ពុំបាននិព្វាន។

៤២. កើតមកជាមនុស្ស វានឹងបានរស់
នៅយូរប៉ុន្មាន គួរគិតរំពឹង
សញ្ជឹងក្នុងប្រាណ តែសីលនិងទាន
បានជាមគ្គផល។

៤៣. បើអ្នកឯណា អាចកាត់តណ្ហា
រួចពីអំពល់ ចំណងច្រវាក់
ក្នុងអកុសល កុំឲ្យអំពល់
នៅលោកិយហោង។

៤៤. រីឯអ្នកនោះ នឹងបានចំពោះ

រួចពីចំណង នៃព្រះយមរាជ
ពុំអាចប៉ុនប៉ង ចាប់អ្នកនោះហោង
ធ្វើទោសឡើយនៃ។

៤៥. ខ្មោចឧស្សាហ៍យក តែតណ្ហាមក
ជាគាប់ប្រពៃ គឺមោះពុំដឹង
វានឹងកើតភ័យ ទៅនរកនៃ
សោយទុក្ខវេទនា។

៤៦. មើលឯយមភូបាល ដុតដែករន្ទាល
ចូលដាប់គ្រប់គ្នា ខ្លះកៀបអណ្តាត
ខ្លះចាប់ហត្ថា ចង់ថ្កុនអាត្មា
បោះទៅក្នុងភ្លើង។

៤៧. ក្សិណរស់ក្សិណស្លាប់ វាចូលទៅចាប់
ត្បិតទាញបានជើង ស្រែកយំបម្រះ
ទធាក់ក្នុងភ្លើង យមភូបាលចាប់ជើង
បោះទៅទៀងហោង។

៤៨. ទម្រាំរដោះ បានរួចពីនោះ
លំបាកណាស់ហោង ឯស្លាប់និងរស់
មួយថ្ងៃមួយរយដង រស់ហើយស្លាប់ផង
ខ្លះស្លាប់ហើយរស់។

៤៩. រីញឥឡូវនេះ ណាកើតជាមនុស្ស
គួរតែអស់អញ ប្រដៅចិត្តឯង
ឲ្យក្រែងបាបមិញ គួរតែស្រឡាញ់
ឯកោរូបា។

៥០. រីឯញាតិដៅ ប្រពន្ធកូនចៅ
មាសប្រាក់ទ្រព្យា មិនបានទៅផង

កំដរទ្បើយហោង ម្តេចមិនអនិច្ចា

រូបឯងទីទៃ។

៥១. ឯមិត្តសម្លាញ់ កាលរស់នៅម៉ិញ

ស្រឡាញ់ឥតក្តី លេបបានខ្ជាក់បាន

ឥតមានសង្ស័យ លុះដល់គ្នាក្ស័យ

ជីវិតមរណា។

៥២. វាប្រែជាស្អប់ ជាខ្លាចស្ញែងស្ញប់

បោះបង់ត្រីហា បើនឹងខំនៅ

រិះរកគ្នីគ្នា កំដរទើបវា

យមភូបាលចាប់ទៅ។

៥៣. ប្រពន្ធសម្លាញ់ កាលរស់នៅម៉ិញ

មិនឲ្យសៅហ្មង រួមរ័កស្នេហា

ទ្វេហានែបនៅ ឥតមានអ្នកក្រៅ

ទៅតាមបីជង់។

៥៤. លុះឯងមរណា ប្រពន្ធនោះវា

អង្គុយប្រែខ្នង វាប្រែជាខ្ពើម

រអើមវិញហោង ហេតុនេះអ្នកផង

គួរគិតអនិច្ចា។

៥៥. វិត្រង់ក្តីស្លាប់ វាមកនៅផ្ទាប់

ខាងអង្គអាត្មា អាជីវស្ងែវ

ទាំងបីនោះណា នោះគឺអាជ្ញា

នៃព្រះយមរាជ។

៥៦. ឲ្យមើលសព្វសីល ក្រែងមនុស្សណាខ្ជិល

ពិតពុំគិតខ្លាច សម្លាប់បំបាត់

អស់មនុស្សសត្វផង បាបធ្ងន់កន្លង

បានស្ថាននរក។

៥៧. ................ បាបលួចប្រពន្ធ
ជូនក្រែកន្លង ដឹកស្រាបាញ់សត្វ
លួចទ្រព្យអ្នកផង បានមកហើយហោង
ចិញ្ចឹមកូនចៅ។

៥៨. អ្នកនោះឯងណា ចិត្តបាបឫស្យា
ពុំដឹងរាក់ជ្រៅ ងងឹតសូន្យសោះ
ចំពោះជាខ្លៅ សោយទុក្ខឥតនៅ
អវីចីនរក។

៥៩. លួចទ្រព្យគេណា ទោះទាំងភរិយា
សឹងតែពុំសុខ នៅនាលោកិយ
នោះក្តីកើតទុក្ខ ស្លាប់ទៅនរក
រងកម្មក្តាត់ក្តៅ។

៦០. ព្រះបន្ទូលថ្លែង ប្រដូចអំបែង
ចាក់ទឹកកំដៅ លើភ្លើងរីងស្ងួត
ជ្រាបជ្រួតទឹកទៅ ឯអំបែងក្តៅ
ចំណោរទៅឆ្ងាយ។

៦១. រីនឹងឧបមា ទឹកកម្មវេរា
បាបទាំងសម្ពាយ ភ្លើងនោះគឺទ្រព្យ
សម្រាប់រូបកាយ ឯអំបែងឆ្ងាយ
គឺអង្គអាត្មា។

៦២. ត្បិតមានបាលី វិសេសប្រពៃ
បន្ទូលទេសនា ទូន្មានអរហន្ត
មហាជននានា ឲ្យគិតអនិច្ចា
សព្វប្រាណទីទៃ។

៦៣. វិបុព្វកំ វិនីលកំ
ឧស្សុំសារេ វិក្ខាយកោ
វ្យចោភារេ លោហិតព្វ
មរណំភវំ។

៦៤. ព្រះបន្ទូលថា សព្វរូបនានា
គួរគិតអនិច្ចំ ស្លាប់ទៅជាខ្មោច
ស្អោកស្គាំងហើមប៉ោង ខ្ពុរទាំងខ្ទុះឈាម
រងែអសោច។

៦៥. ................. មានគ្រប់ប្រការ
ជំពូកទីទៃ ហេតុនោះគួរគិត
អាណិតរូបក្រៃ រស់នៅសព្វថ្ងៃ
ស្អិតស្អាងអាត្មា។

៦៦. ស្លាប់ទៅដេកដី អស់ម្រឹគបក្សី
ទំនើងភោក្តា ចឹកជាន់ជញ្ជែង
ឥតក្រែងឡើយណា តាមតែចិត្តវា
ហែកហួរទីទៃ។

៦៧. ឯខ្ទុះនិងឈាម វាហូររហាម
ជ្រាបទៅដោយដី ចចកស្វានស្វា
ទំពារជើងដៃ ផ្តាច់ចេញទីទៃ
តាមតែចិត្តវា។

៦៨. កើតមកជាមនុស្ស ពុំស្គាល់កំហុស
សង្វេគអនិច្ចា អាងតែមានទ្រព្យ
គិតស្មានថាជា គឺមោះឥតការ
ដូចនិទានមក។

៦៩. ខំទាំងយប់ថ្ងៃ នឿយណាស់ល្វិតល្វៃ

សន្សំរើសរក　　បានគួរធ្វើបុណ្យ
ទុកទៅបរលោក　　ម្ដេចខំបានមក
ទិញឯស្រាផឹក។

៣០. ពោលពាក្យប្រមាថ　　ស្រដីវិវាទ
សើចស្រួលរអឹក　　ដៀលអ្នកមានសីល
ថាខ្ជិលប្រមឹក　　ដើររករអឹក
ឯងដេកតែផី។

៣១. ស្រដីមុសា　　សព្វទិនទិវា
ពុំគិតចំណេះ　　ទៀងទៅឯមុខ
រងទុក្ខស្តិតស្តេរ　　នរកតែងផី
ខ្ទុះឈាមសព្វថ្ងៃ។

៣២. ងងឹតឈឹងឈប់　　ហាក់ដូចកលយប់
ជាអចិន្ត្រៃ　　.....................
កាលក្ដីពុំភ្លេច　　ម្ដេចឡើយអាស្រ័យ
ពុំគិតបុណ្យបាប។

៣៣. ឲ្យចាំទុក្ខំ　　ឲ្យចាំអនិច្ចំ
អនត្តាជរាប　　ដល់យាវជីវំ
ធម្មំសុភាព　　ហើយដោះបាបបាន
ត្រៃលក្ខណាញាណា។

៣៤. ហើយឲ្យភាវនា　　រំឭកគាថា
បីបទប្រធាន　　ផលទៅឯមុខ
សង់ទុកជាស្ពាន　　ហើយអ្នកនោះ
បាននិព្វានថ្លៃថ្លា។

៣៥. អវិជ្ជាឧប្បណ្ណា　　បិលតោអនិច្ចំ
មរណាសព្វរោគា　　ព្យាធិបនទៀរ

សុចំសុខា អកុសលំ

......................។

៧៦. នៃទឹងសម្តែង និទានថ្លាថ្លែង

អង្គអគ្គរំ អ្នកអកុសល

អសទ្ធារំ ទុរបុញ្ញំ

ទុរនិច្ចតោ ។

៧៧. ច្ងាយហើយវែងច្ងាយ អស់សត្វទាំងឡាយ

ពុំគិតកាយោ វាចំមនស

វរវុធោ អយំគន្ធោ

មរណិយេ ។

៧៨. នរអ្នកណា មែនមានប្រាជ្ញា

មើលហើយឲ្យប្រែ អស់អាថ៌បាលី

នេះនៃឲ្យថៃ មើលហើយមិនប្រែ

នោះហៅភ្លេចច្បាប់។

៧៩. គឺមោះប្រាជ្ញា គិតហើយពិចារណា

ថាល្អគួរគាប់ បើស្រឡាញ់ខ្លួន

ស្ងួនយកជាច្បាប់ ខ្មៅថាពុំគាប់

តិចចិត្តសទ្ធា។

៨០. ប្រាថ្នានិព្វាន ប្រាថ្នាឲ្យបាន

សម្បត្តិសួគ៌ា លុះតែអស់អញ

លំគេញអាត្មា នឹងគុណពុទ្ធា

រ័ត្នត្រៃទាំងបី។

៨១. គុណគ្រូបាធ្យាយ គុណអាពុកម្តាយ

ព្រះពាយធរណី ព្រះពៃស្រពណ៍ស្រេច

នៅព្រះអគ្គី　　　　នឹកគុណប្រក្រតី
សព្វទិនទិវា។

៨២. នរអ្នកផង　　　　ត្រេកត្រអាលផ្គងផ្គង
លុតលើកហត្ថា　　　　គួររួចប្រណិប័ត
ធ្វើវត្តវន្ទា　　　　នឹកគុណទេវា
សព្វថ្ងៃប្រក្រតី។

៨៣. អ្នកនោះឯងណា　　　　ទោះនឹងប្រាថ្នា
សម្បត្តិទាំងបី　　　　សម្បត្តិមនុស្សលោក
នោះសោតប្រពៃ　　　　ឥតទុក្ខឥតភ័យ
បៀតបៀនឡើយណា។

៨៤. លុះលែងជាតិទៅ　　　　នឹងស្ថិតនិត្យនៅ
សម្បត្តិសួគ៌ា　　　　រៀងរួចលុះបាន
និព្វានថ្លៃថ្លា　　　　ដូចចិត្តប្រាថ្នា
ពិតពុំឃ្លាតឡើយ។

៨៥. ហៃអស់អ្នកផង　　　　ចូរស្តាប់ត្រាប់ត្រង
កុំបីព្រងើយ　　　　អស់អាថ៌វាចា
សុរេចម្លេះហើយ　　　　គាថាជាត្រើយ
បរបូណ៌ស្រេចហោង៕